ដាក់លាក់បានឡើយ។  បន្ទាប់ពីយើងបញ្ចប់ការពិនិត្យមើលឡើងវិញ នូវការដាក់ពាក្យសុំរបស់អ្នក និងសំរេចថាការរ៉ាប់រងសុខភាពណាមួយ ដែលរូបអ្នក ឬគ្រួសាររបស់អ្នកអាចទទួលបាន អ្នកនឹងទទួលសំបុត្រមួយច្បាប់ដែលប្រាប់អ្នកអំពីអ្វីៗ ដែលបានសំរេច។  សំបុត្រនោះក៏នឹងប្រាប់អ្នក អំពីរបៀបចាប់ផ្តើមប្រើការរ៉ាប់រងសុខភាពរបស់អ្នក ឬរបៀបតវ៉ាការសំរេចរបស់យើង បើអ្នកមិនយល់ស្របជាមួយនឹងការសំរេចនេះ។  បើរូបអ្នក ឬជនណាម្នាក់ក្នុងគ្រួសាររបស់អ្នកមានសិទ្ធិទទួល Medi-Cal អ្នកនឹងទទួល អត្តសញ្ញាណប័ណ្ណអត្ថប្រយោជន៍ Medi-Cal (Medi-Cal Benefits Identification Card, BIC)តាមសំបុត្រ។ អ្នកអាចនឹងទទួលប័ណ្ណ BIC របស់អ្នក មុនពេលអ្នកទទួលសំបុត្រ ដែលថ្លែងថាអ្នកមានសិទ្ធិទទួល Medi-Cal ហើយបើដូច្នេះមែន អ្នកអាចនឹងចាប់ផ្តើមប្រើវានៅពេលបានទទួល។  បើអ្នកមានប័ណ្ណ BIC ចាស់ វានឹងត្រូវបានធ្វើឲ្យប្រើការបានវិញ។ បើអ្នកធ្លាប់មានប័ណ្ណ BIC ពីមុន ប៉ុន្តែលែងមានវាទៀត អ្នកអាចទាក់ទងភ្នាក់ងារសេវាមនុស្សនៅខោនធីរបស់អ្នក ដើម្បីស្នើសុំប័ណ្ណមួយថ្មី បន្ទាប់ពីការដាក់ពាក្យសុំរបស់អ្នកត្រូវបានយល់ព្រម។

**ចុះបើសិនខ្ញុំត្រូវការថែទាំសុខភាព ក្នុងកាលខ្ញុំកំពុងរង់ចាំ?**

បើអ្នកត្រូវការព្យាបាលសុខភាពនៅឥឡូវនេះ អ្នកគួរតែទៅជួបវេជ្ជបណ្ឌិត គ្លីនិកសុខភាព ឬមន្ទីរពេទ្យ។  ត្រូវរក្សាទុកបង្កាន់ដៃទាំងពួង សំរាប់អ្វីៗដែលអ្នកបង់ប្រាក់សំរាប់ការព្យាបាល។  បើអ្នកមានសិទ្ធិទទួល Medi-Cal អ្នកអាចនឹងបានប្រាក់វិញសំរាប់សេវាថែទាំសុខភាពដែលអ្នកបានបង់។  បើអ្នកត្រូវការព្យាបាល ហើយអ្នកទៅជួបវេជ្ជបណ្ឌិត ឬគ្លីនិក ដែលទទួលយក Medi-Cal ជាការធានារ៉ាប់រង គេអាចជួយអ្នកឲ្យទទួលប្រាក់វិញនៅពេលក្រោយ បើត្រូវបានរកឃើញថាអ្នកមានសិទ្ធិទទួល Medi-Cal។  បើអ្នកត្រូវការថែទាំសុខភាពជាបន្ទាន់ ប៉ុន្តែមិនអាចទទួលវាបាន ដោយគ្មានការធានារ៉ាប់រង សូមទូរស័ព្ទទៅភ្នាក់ងារសេវាមនុស្សនៅខោនធីរបស់អ្នក តាមលេខទូរស័ព្ទនៅក្នុងបញ្ជីខោនធី ដែលមានភ្ជាប់មកជាមួយ និងសូមឲ្យគេពិនិត្យមើលការដាក់ពាក្យសុំរបស់អ្នកឡើងវិញ ឲ្យឆាប់រហ័សថែមទៀត ពីព្រោះអ្នកត្រូវការព្យាបាលសុខភាពជាបន្ទាន់។

**ចុះបើសិនខ្ញុំមានវិក្កយប័ត្រពេទ្យ សំរាប់ការថែទាំសុខភាព ដែលខ្ញុំបានទទួលក្នុងកាលកំពុងរង់ចាំ?**

បើអ្នកត្រូវបានរកឃើញថាមានសិទ្ធិទទួល Medi-Cal នោះការរ៉ាប់រងរបស់អ្នកនឹងបកទៅខែដែលអ្នកបាន ដាក់ពាក្យសុំ។ អ្នកអាចសូមវេជ្ជបណ្ឌិតរបស់អ្នក ឲ្យចេញវិក្កយប័ត្រទៅ Medi-Cal សំរាប់ការថែទាំសុខភាពដែលអ្នកបានទទួល ក្នុងកាលកំពុងរង់ចាំ។  អ្នកក៏អាចនឹងបានប្រាក់វិញដែរ បើអ្នកបានបង់ថ្លៃសេវាថែទាំសុខភាព។  លើសពីនេះទៀត បើអ្នកត្រូវបានយល់ព្រមសំរាប់ Medi-Cal និងមានសិទ្ធិទទួលការរ៉ាប់រងបកក្រោយ Medi-Cal ក៏អាចនឹងជួយអ្នកបង់ថ្លៃសេវាសុខភាពភាគច្រើនដែលអ្នកបានទទួល ចំនួនបីខែមុនពេលអ្នកបានដាក់ពាក្យសុំដែរ។  សំរាប់ព័ត៌មានបន្ថែម សូមទៅមើល www.healthconsumer.org។

បើនៅពេលបច្ចុប្បន្ននេះ អ្នកមានវិក្កយប័ត្រពេទ្យ អ្នកអាច :

1) ទូរស័ព្ទទៅលេខនៅលើវិក្កយប័ត្រ និងប្រាប់គេថាអ្នកកំពុងរង់ចាំការឮដំណឹង អំពីសិទ្ធិទទួល Medi-Cal របស់អ្នក។ សូមកុំឲ្យគេផ្ញើវិក្កយប័ត្ររបស់អ្នក ទៅភ្នាក់ងារប្រមូលបំណុល។  អ្នកក៏អាចផ្ញើសំណៅនៃសំបុត្រនេះទៅគេបានដែរ។
2) អ្នកក៏គួរតែទាក់ទងភ្នាក់ងារសេវាមនុស្សនៅខោនធីរបស់អ្នកដែរ បើអ្នកត្រូវបានរកឃើញថាមានសិទ្ធិទទួល Medi-Cal ដើម្បីប្រាប់គេឲ្យដឹង ថាអ្នកមានវិក្កយប័ត្រពេទ្យ និងខែថ្ងៃឆ្នាំ ដែលអ្នកបានទទួលការថែទាំសុខភាព (មិនមែនខែថ្ងៃឆ្នាំនៃវិក្កយប័ត្រ)។  យ៉ាងនេះនឹងជាជំនួយខ្លាំងសំរាប់ការសំរេច បើអ្នកមានសិទ្ធិទទួលការរ៉ាប់រងបកក្រោយ។

**តើខ្ញុំនឹងត្រូវបង់ពិន័យពន្ធដារ សំរាប់ការពុំមានការធានារ៉ាប់រង ក្នុងកាលខ្ញុំកំពុងរង់ចាំឬទេ?**

អ្នកនឹងមិនត្រូវបង់ពិន័យពន្ធដារ សំរាប់ខែមុនពីៗមក ដែលអ្នកពុំមានការធានារ៉ាប់រង ពីព្រោះអ្នកបានដាក់ពាក្យសុំ ក្នុងពេលការបើកចុះឈ្មោះក្នុងឆ្នាំ 2014 ទេ ហើយក៏នៅតែរង់ចាំចំឡើយពីយើង។  នៅក្រោមច្បាប់សុខាភិបាលថ្មី មនុស្សភាគច្រើនត្រូវតែមានការធានារ៉ាប់រងសុខភាពនៅឆ្នាំនេះ ឬនឹងត្រូវបង់ពិន័យពន្ធដារ ក្នុងខែមេសា ឆ្នាំ 2015។  អ្នកក៏អាចនឹងជៀសវាងការបង់ពិន័យពន្ធដារដែរ បើអ្នកមានមូលហេតុផ្សេងទៀត ដែលអ្នកមិនអាចទទួលការធានារ៉ាប់រងនៅឆ្នាំនេះបាន។  បើអ្នកមានសំណួរអ្វី អ្នកអាចទាក់ទង សម្ព័ន្ធសុខភាពអតិថិជន (Health Consumer Alliance) តាមលេខ 1-888-804-3536។

**តើខ្ញុំអាចទទួលព័ត៌មាន អំពីការដាក់ពាក្យសុំរបស់ខ្ញុំ នៅឯណា?**

ទូរស័ព្ទទៅភ្នាក់ងារសេវាមនុស្សនៅខោនធីរបស់អ្នក តាមលេខទូរស័ព្ទនៅក្នុងបញ្ជីខោនធី ដែលមានភ្ជាប់មកជាមួយ សំរាប់ព័ត៌មានអំពីការដាក់ពាក្យសុំរបស់អ្នក។  សូមជ្រាបថាវាជាសារៈសំខាន់ ដែលអ្នកមិនបញ្ជូនការដាក់ពាក្យសុំបន្ថែមទៀត ក្នុងកាលកំពុងរង់ចាំ ការតបឆ្លើយ។  ការធ្វើយ៉ាងនេះ អាចបណ្តាលឲ្យរឹតតែពន្យារពេល ក្នុងការពិនិត្យមើលពាក្យសុំ ដែលអ្នកបានបញ្ជូនមករួចហើយ។

**Department of Health Care Services**
1501 Capitol Avenue, MS 4607
Sacramento, CA 95899-7417

State of California—Health and Human Services Agency
Department of Health Care Services

**TOBY DOUGLAS**
*DIRECTOR*

**EDMUND G. BROWN JR.**
***GOVERNOR***

# ព័ត៌មានដ៏សំខាន់ អំពីការដាក់ពាក្យសុំរបស់អ្នក សំរាប់ការធានារ៉ាប់រងសុខភាព

ខែថ្ងៃឆ្នាំ : 08/14/2014

ជូនចំពោះអ្នកដាក់ពាក្យសុំ :

យើងសូមអរគុណអ្នក ចំពោះការដាក់ពាក្យសុំការធានារ៉ាប់រងសុខភាពមានតម្លៃសមរម្យ នៅក្នុងរដ្ឋកាលីហ្វ័រនីញ៉ា។ យើងដឹងថាអ្នក ឬសមាជិកគ្រួសាររបស់អ្នក កំពុងរង់ចាំដើម្បីយល់ដឹងថាការធានារ៉ាប់រងសុខភាពអ្វីខ្លះ ដែលអ្នកអាចទទួលនៅឆ្នាំនេះ និងថាតើអ្នកអាចទទួលអត្ថប្រយោជន៍ Medi-Cal ឬអត់។

**តើមានអ្វីបានកើតឡើង ចំពោះការដាក់ពាក្យសុំការធានារ៉ាប់រងសុខភាពរបស់ខ្ញុំ?**

យើងសូមអភ័យទោសដែលអ្នកមិនបានឮដំណឹងពីយើងវិញ អំពីការដាក់ពាក្យសុំ Medi-Cal របស់អ្នក។ គួរឲ្យសោកស្តាយណាស់ ពីព្រោះយើងបានទទួលការដាក់ពាក្យសុំច្រើនណាស់ និងពីព្រោះមានបញ្ហានឹងកុំព្យូទ័រ ហើយយើងមិនបានបញ្ចប់នូវដំណើរការដាក់ពាក្យសុំទាំងអស់។ យើងចង់ប្រាប់អ្នកឲ្យដឹង ថាយើងមានពាក្យសុំរបស់អ្នក ហើយយើងនឹងធ្វើការសំរេចយ៉ាងឆាប់រហ័សបំផុត អំពីការរ៉ាប់រងសុខភាពអ្នក ឬគ្រួសាររបស់អ្នក ដោយយោងទៅលើព័ត៌មានដែលអ្នកបានផ្តល់ឲ្យយើង។ **អ្នកមិនបាច់ដាក់ពាក្យសុំម្តងទៀតឡើយ។**

**តើអ្នកត្រូវការព័ត៌មានថែមទៀតពីខ្ញុំ អំពីការដាក់ពាក្យសុំរបស់ខ្ញុំឬទេ?**

បើយើងត្រូវការព័ត៌មានថែមទៀត យើងនឹងផ្ញើសំបុត្រទៅឲ្យអ្នក ស្នើព័ត៌មានដែលយើងត្រូវការ ដើម្បីបញ្ចប់ធ្វើការសំរេច ថាតើអ្នកអាចទទួលអត្ថប្រយោជន៍ Medi-Cal ឬអត់។ បើអ្នកបានទទួលសំបុត្រស្នើសុំព័ត៌មានបន្ថែម សូមតបឆ្លើយទៅមនុស្សទំនាក់ទំនងនៅលើសំបុត្រនោះ ជាមួយនឹងព័ត៌មានដែលត្រូវការ។ បើយើងមិនបានទទួលព័ត៌មានពីអ្នក ឲ្យទាន់កាលបរិច្ឆេទបានកំណត់នៅលើសំបុត្រនោះទេ យើងនឹងបដិសេធការដាក់ពាក្យសុំរបស់អ្នក។ បើយើងមិនបានសូមឲ្យអ្នកផ្តល់ព័ត៌មានថែមទៀត ចូរកុំបារម្ភឡើយ។ នេះមានសេចក្តីថា យើងមានអ្វីៗដែលយើងត្រូវការ រីឯការដាក់ពាក្យសុំរបស់អ្នកនឹងបានពិនិត្យមើល ហើយយើងនឹងផ្ញើចំឡើយទៅឲ្យអ្នក យ៉ាងឆាប់រហ័សតាមលទ្ធភាពយើងអាចធ្វើបាន។

**តើខ្ញុំនឹងទទួលចំឡើយ អំពីការដាក់ពាក្យសុំរបស់ខ្ញុំ នៅពេលណា?**

យើងសង្ឃឹមថានឹងធ្វើការសំរេចអំពីការដាក់ពាក្យសុំរបស់អ្នកយ៉ាងឆាប់រហ័សបំផុត ប៉ុន្តែយើងមិនអាចប្រាប់អ្នកអំពីកាលបរិច្ឆេទ